**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

លេខ.០១១៣.....សហវ..........

# សេចក្ដីណែនាំ

## ស្ដីពី

## ការអនុវត្តនីតិវិធីថ្មីសម្រាប់ការចំណាយទូទាត់ត្រង់ដែលមានហានិភ័យទាប សម្រាប់ក្រសួង-ស្ថាប័នចំនួន ១៩ តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS)

បន្ទាប់ពីបានអនុវត្តដោយជោគជ័យ នូវនីតិវិធីថ្មីសម្រាប់ការចំណាយទូទាត់ត្រង់ដែលមានហានិភ័យទាបតាមប្រព័ន្ធ FMIS ទាំងស្រុងនៅក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ក្រសួងចំនួន ៧ (រួមទាំងអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញថ្នាក់កណ្ដាល) ដោយក្នុងនោះ រួមមាន ១-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ២-ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ៣-ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ៤-ក្រសួងមុខងារសាធារណៈ ៥-ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ៦-ក្រសួងសុខាភិបាល និង ៧-ក្រសួងអប់រំ យុវជន និងកីឡា ក្នុងឆ្នាំ ២០២០ រួចមក និងស្របតាមផែនការយុទ្ធសាស្ត្រតម្រង់ទិសនីតិវិធីអនុវត្តការងារ តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ២០២០-២០២៥ ក្នុងក្របខណ្ឌនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាលកម្ពុជា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងបន្តអនុវត្តនីតិវិធីនេះទៅក្រសួង-ស្ថាប័នចំនួន ១៩ បន្ថែម (រួមទាំង អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញនៅថ្នាក់កណ្ដាល) រួមមាន ១-ក្រសួងព្រះបរមរាជវាំង ២-រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ៣-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ៤-ក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ៥-ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ៦-ក្រសួងរ៉ែ និងថាមពល ៧-ក្រសួងផែនការ ៨-ក្រសួងពាណិជ្ជកម្ម ៩-ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ១០-ក្រសួងបរិស្ថាន ១១-ក្រសួងអភិវឌ្ឍន៍ជនបទ ១២-ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ១៣-ក្រសួងធម្មការ និងសាសនា ១៤-ក្រសួងកិច្ចការនារី ១៥-ក្រសួងសាធារណការ និងដឹកជញ្ជូន ១៦-ក្រសួងទេសចរណ៍ ១៧-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ១៨-ក្រសួងធនធានទឹក និងឧតុនិយម និង ១៩-ក្រសួងព័ត៌មាន ។ អង្គភាពដែលត្រូវចូលរួមអនុវត្តនីតិវិធីតម្រង់ទិសថ្មីនេះ រួមមាន អង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ ឬ អង្គភាពថវិកាជាអាណាប័កផ្ទេរសិទ្ធិពេញលេញនៅថ្នាក់កណ្ដាលដែលទទួលបានការប្រគល់សិទ្ធិពីអាណាប័កដើមខ្សែនៃក្រសួង-ស្ថាប័នទាំង ១៩ លើមុខសញ្ញាចំណាយនៅក្នុងសេចក្ដីណែនាំនេះ រួមទាំងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអមក្រសួង-ស្ថាប័នទាំង ១៩ នៃនាយកដ្ឋានហិរញ្ញកិច្ច និង អគ្គនាយកដ្ឋានរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមធ្វើការណែនាំដូចតទៅ÷

**១.** នីតិវិធីអនុវត្តការងារថ្មីនេះ គ្របដណ្ដប់លើមុខសញ្ញាចំណាយដែលមិនមានការស្នើសុំធានាចំណាយដោយឡែកពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង មានមាតិកាថវិកាចំណាយតាមអនុគណនី និង អត្ថគាហកៈ ដូចខាងក្រោម÷

| អនុគណនី | បរិយាយ | អត្ថគាហកៈ |
|---|---|---|
| 60061 | ថ្លៃប្រើប្រាស់អគ្គិសនី ដែលផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជា និង សាខារបស់ខ្លួននៅតាមបណ្ដារាជធានី-ខេត្ត | អគ្គិសនីកម្ពុជា ឬ សាខាអគ្គិសនីកម្ពុជា |

២

| | | |
|---|---|---|
| 60062 | ថ្លៃប្រើប្រាស់ទឹកស្អាត ដែលផ្គត់ផ្គង់ដោយរដ្ឋាករទឹកស្វយ័តក្រុង និង សាខារបស់ខ្លួនតាមបណ្តារាជធានី-ខេត្ត | រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ និង រដ្ឋាករទឹកស្វយ័តខេត្ត ក្រោមការគ្រប់គ្រងរបស់មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ |
| 61011 | ថ្លៃប្រមូលសំរាម និង កាកសំណល់ ដែលមានកិច្ចសន្យា ឬ កិច្ចព្រមព្រៀង | រដ្ឋាករស្វយ័តគ្រប់គ្រងសំរាម និងសំណល់រឹងរាជធានីភ្នំពេញ ឬ ក្រុមហ៊ុនដែលមានកិច្ចសន្យា និង កិច្ចព្រមព្រៀង |
| 61092 | ប្រាក់កម្រៃភ្នាក់ងារបរទេសជាប់កិច្ចសន្យា ដែលមានគោលការណ៍ពីរាជរដ្ឋាភិបាល | |
| 61113 | ថ្លៃជាវសៀវភៅរាជកិច្ច ដែលផ្គត់ផ្គង់ដោយទីស្តីការគណៈរដ្ឋមន្ត្រី | |
| 61141 | សោហ៊ុយប្រៃសណីយ៍ ដែលផ្តល់សេវាដោយប្រៃសណីយកម្ពុជា | ប្រៃសណីយ៍កម្ពុជា |
| 61142 | សោហ៊ុយទូរគមនាគមន៍ ដែលផ្តល់សេវាដោយក្រុមហ៊ុនទូរគមនាគមន៍កម្ពុជា | ទូរគមនាគមន៍កម្ពុជា ឬ និយ័តករទូរគមនាគមន៍កម្ពុជា |
| 62025 | ប្រាក់អាហារូបករណ៍សម្រាប់ការសិក្សា និង ស្រាវជ្រាវក្នុងប្រទេស ដែលមានគោលរបបកំណត់ | |
| 63011 | លតាប័ត្រសម្រាប់ចំណាយលើការបង់ពន្ធយានយន្តប្រចាំឆ្នាំ (មធ្យោបាយដឹកជញ្ជូន) ដែលជាកម្មសិទ្ធិរបស់ក្រសួង | អគ្គនាយកដ្ឋានពន្ធដារ ឬ សាខាពន្ធដារ |

**២.អង្គភាពថវិកាជាអាណាប័កផ្ទេរសិទ្ធិពេញលេញនៅថ្នាក់កណ្តាល ដែលទទួលបានការប្រគល់សិទ្ធិពីអាណាប័កដើមខ្សែ លើមុខសញ្ញាចំណាយនៅក្នុងសេចក្តីណែនាំនេះ ដែលមិនទាន់ប្រើប្រាស់ប្រព័ន្ធ FMIS** នៅរក្សានីតិវិធីអនុវត្តការងារបច្ចុប្បន្នផ្ទៃក្នុងដដែល ប៉ុន្តែត្រូវបញ្ជូនសំណុំឯកសារអាណត្តិបើកប្រាក់ទៅអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ នៃក្រសួង-ស្ថាប័នសាមី ដើម្បីបន្តដំណើរការនីតិវិធីនៅក្នុងប្រព័ន្ធ FMIS ។

**៣.អង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ** ត្រូវអនុវត្តដូចខាងក្រោម÷

*ក. ករណីទី១. ចំណាយទូទាត់ត្រង់ ដែលទទួលបន្ទុកដោយអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុផ្ទាល់*

-អ្នកទទួលបន្ទុកចុះប្រតិបត្តិការចំណាយទូទាត់ត្រង់ (ដូចមានចែងក្នុងចំណុចលេខ ១ ខាងលើ) ត្រូវប្រមូលឯកសារពាក់ព័ន្ធនឹងចំណាយទាំងនោះ រួចធ្វើការបង្កើតប្រតិបត្តិការចំណាយនៅក្នុងប្រព័ន្ធ FMIS ដោយបំពេញបន្ថែមព័ត៌មានចាំបាច់នានានៅក្នុងប្រតិបត្តិការផ្ទាល់ឱ្យបានត្រឹមត្រូវច្បាស់លាស់ និង ស្កេនលិខិតយុត្តិការចំណាយមួយចំនួនបញ្ចូលទៅក្នុងប្រព័ន្ធ FMIS ដូចមានលម្អិតក្នុងឧបសម្ព័ន្ធនៃសេចក្តីណែនាំនេះ ដើម្បីជាមូលដ្ឋានក្នុងការពិនិត្យទូទាត់ និង ធ្វើសវនកម្មតាមប្រព័ន្ធ FMIS រួចបញ្ជូនទៅកាន់អ្នកអនុម័តជាអាណាប័កផ្ទេរសិទ្ធិ ដោយមិនមានរៀបចំសំណុំឯកសារអាណត្តិបើកប្រាក់ខាងក្រៅប្រព័ន្ធ FMIS ឡើយ ។ លិខិតយុត្តិការចំណាយច្បាប់ដើម ត្រូវបានអនុញ្ញាតឱ្យរក្សាទុកនៅអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ ដើម្បីជាកម្មវត្ថុនៃការធ្វើអធិការកិច្ច ឬ សវនកម្ម ។

-អ្នកអនុម័តជាអាណាប័កផ្ទេរសិទ្ធិ ធ្វើការត្រួតពិនិត្យ និង អនុម័តប្រតិបត្តិការចំណាយខាងលើនៅក្នុងប្រព័ន្ធ FMIS ជាផ្លូវការដោយពុំរង់ចាំឯកសារជាក្រដាសនោះទេ រួចបញ្ជូនបន្តទៅអភិបាលហិរញ្ញវត្ថុដែលជាមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ២
អមក្រសួង-ស្ថាប័នទាំង ១៩ តាមប្រព័ន្ធ FMIS ។

*ខ. ករណីទី២. ចំណាយទូទាត់ត្រង់ ដែលទទួលបន្ទុកដោយអង្គភាពថវិកាជាអាណាប័កផ្ទេរសិទ្ធិនៅថ្នាក់កណ្ដាល ដែលមិនទាន់ប្រើប្រាស់ប្រព័ន្ធ FMIS*

អ្នកទទួលបន្ទុកចុះប្រតិបត្តិការត្រូវបង្កើតប្រតិបត្តិការចំណាយនៅក្នុងប្រព័ន្ធ FMIS ទៅតាមមុខសញ្ញាចំណាយ ដូចមានចែងក្នុងចំណុចទី១ បន្ទាប់ពីទទួលបាននូវសំណុំឯកសារអាណត្តិបើកប្រាក់ពីអង្គភាពថវិកាជាអាណាប័កផ្ទេរសិទ្ធិ ដោយបំពេញបន្ថែមព័ត៌មានចាំបាច់នានានៅក្នុងប្រតិបត្តិការផ្ទាល់ឱ្យបានត្រឹមត្រូវច្បាស់លាស់ និងត្រូវស្កេនភ្ជាប់មកជាមួយនូវលិខិតយុត្តិការចំណាយមួយចំនួន ដូចមានលម្អិតក្នុងឧបសម្ព័ន្ធនៃសេចក្ដីណែនាំនេះ ដើម្បីជាមូលដ្ឋានពិនិត្យទូទាត់ និង ធ្វើអធិការកិច្ច ឬសវនកម្មតាមប្រព័ន្ធ FMIS រួចបញ្ជូនទៅកាន់អ្នកអនុម័តជាអាណាប័កផ្ទេរសិទ្ធិ ដោយមិនបញ្ជូនសំណុំឯកសារច្បាប់ដើមទាំងនោះបន្តទៀតនោះទេ ។ លិខិតយុត្តិការចំណាយច្បាប់ដើម ត្រូវបានអនុញ្ញាតឱ្យរក្សាទុកនៅសាមីអង្គភាព ដើម្បីជាកម្មវត្ថុនៃការធ្វើអធិការកិច្ច ឬសវនកម្ម។

-អ្នកអនុម័តជាអាណាប័កផ្ទេរសិទ្ធិ នៃអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ ធ្វើការត្រួតពិនិត្យ និង អនុម័តលើប្រតិបត្តិការចំណាយនៅក្នុងប្រព័ន្ធ FMIS ជួសមុខឱ្យអង្គភាពថវិកាជាអាណាប័កផ្ទេរសិទ្ធិ ដោយពុំរង់ចាំឯកសារជាក្រដាសនោះទេ រួចបន្តទៅកាន់អភិបាលហិរញ្ញវត្ថុ ដែលជាមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអមក្រសួង-ស្ថាប័នទាំង ១៩ តាមប្រព័ន្ធ FMIS ។

**៤.អង្គភាពថវិកាជាអាណាប័កផ្ទេរសិទ្ធិនៅថ្នាក់កណ្ដាល ដែលទទួលបានការប្រគល់សិទ្ធិពីអាណាប័កដើមខ្សែលើមុខសញ្ញាចំណាយនៅក្នុងសេចក្ដីណែនាំនេះ ដែលបានប្រើប្រាស់ប្រព័ន្ធ FMIS** ត្រូវអនុវត្តដូចគ្នានឹងករណីទី១ នៃចំណុចទី៣ ខាងលើ តែស្ថិតនៅក្នុងក្របខណ្ឌអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិសាមីដោយផ្ទាល់ ។

**៥. មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអមក្រសួង-ស្ថាប័នទាំង ១៩** ត្រូវធ្វើការត្រួតពិនិត្យ និងអនុម័តប្រតិបត្តិការចំណាយខាងលើក្នុងនាមជាអភិបាលហិរញ្ញវត្ថុជាផ្លូវការនៅក្នុងប្រព័ន្ធ FMIS បន្ទាប់ពីទទួលបាននូវប្រតិបត្តិការចំណាយដែលបញ្ជូនពីអាណាប័កផ្ទេរសិទ្ធិ ដោយគ្មានឯកសារជាក្រដាសនោះទេ រួចបញ្ជូនបន្តតាមប្រព័ន្ធ FMIS ទៅអគ្គនាយកដ្ឋានរតនាគារជាតិ ។

**៦.អគ្គនាយកដ្ឋានរតនាគារជាតិ** ធ្វើការពិនិត្យ និង ទូទាត់ចំណាយក្នុងនាមគណនេយ្យករសាធារណៈ ដូចខាងក្រោម÷

*ក. នៅដំណាក់កាលប្រតិបត្តិការចំណាយថវិកា*

អ្នកទទួលបន្ទុកត្រួតពិនិត្យ និង កាត់ពន្ធ ត្រូវបន្តពិនិត្យ និង កាត់ពន្ធក្នុងប្រតិបត្តិការចំណាយខាងលើក្រោយពេលទទួលបានប្រតិបត្តិការពីអភិបាលហិរញ្ញវត្ថុតាមប្រព័ន្ធ FMIS ដោយគ្មានឯកសារជាក្រដាសនោះទេ រួចបញ្ជូនទៅកាន់អ្នកអនុម័តប្រតិបត្តិការចំណាយតាមប្រព័ន្ធFMIS ។ អ្នកអនុម័តប្រតិបត្តិការចំណាយតាមប្រព័ន្ធFMIS ត្រូវបន្តពិនិត្យ និង អនុម័តប្រតិបត្តិការចំណាយខាងលើនៅក្នុងប្រព័ន្ធ FMIS ជាផ្លូវការតែម្ដង ដោយគ្មានឯកសារជាក្រដាសនោះទេ និង បន្តបញ្ចប់ប្រតិបត្តិការចំណាយថវិកាតាមនីតិវិធីក្នុងប្រព័ន្ធ FMIS រួចបញ្ជូនបន្តតាមប្រព័ន្ធ FMIS ទៅកាន់អ្នកអនុវត្តប្រតិបត្តិការទូទាត់ចំណាយ ។

*ខ. នៅដំណាក់កាលប្រតិបត្តិការទូទាត់ចំណាយ*

**ករណីទី១÷ ការទូទាត់ជាសាច់ប្រាក់**

១-ដោយប្រើប្រាស់ការទូទាត់តាមអេឡិចត្រូនិក (Electronic Fund Transfer) ÷ ក្រោយពីទទួលបានការជូនដំណឹងអំពីការទូទាត់ចំណាយខាងលើ អ្នករៀបចំការទូទាត់ ត្រូវបង្កើតប្រតិបត្តិការទូទាត់សាច់ប្រាក់ក្នុងប្រព័ន្ធ FMIS ដោយប្រើប្រាស់វិធីសាស្ត្របង្វែរសាច់ប្រាក់អេឡិចត្រូនិក (Electronic Fund Transfer) រួចបញ្ជូនទៅកាន់អ្នកអនុម័តប្រតិបត្តិការទូទាត់សាច់ប្រាក់ ដើម្បីពិនិត្យ និង បង្វែរទៅធនាគារជាតិនៃកម្ពុជា ឬ ធនាគារពាណិជ្ជជាដៃគូ ។ ៣

ខាងលើ អ្នករៀបចំការទូទាត់ ត្រូវបង្កើតប្រតិបត្តិការទូទាត់សាច់ប្រាក់ក្នុងប្រព័ន្ធ FMIS ដោយប្រើប្រាស់វិធីសាស្ត្របោះផ្សាយមូលប្បទានបត្រ (System Check) រួចបញ្ជូនទៅកាន់អ្នកអនុម័តប្រតិបត្តិការទូទាត់សាច់ប្រាក់ដើម្បីពិនិត្យ និង អនុម័ត ។ ក្រោយប្រតិបត្តិការទូទាត់សាច់ប្រាក់បានអនុម័តរួច អ្នកបង្កើតប្រតិបត្តិកាធ្វើការបោះពុម្ពមូលប្បទានបត្រជូនអ្នកផ្គត់ផ្គង់ ។

**ករណីទី២÷ ការទូទាត់មិនមែនជាសាច់ប្រាក់**

១-ទូទាត់ចូលគណនីប្រាក់បញ្ញើរបស់អ្នកផ្គត់ផ្គង់មាននៅរតនាគារថ្នាក់កណ្ដាល÷ ក្រោយពីទទួលបានការជូនដំណឹងអំពីការទូទាត់ចំណាយខាងលើ អ្នករៀបចំការទូទាត់ ត្រូវបង្កើតប្រតិបត្តិការទូទាត់ក្នុងប្រព័ន្ធ FMIS ចូលគណនីប្រាក់បញ្ញើរបស់អ្នកផ្គត់ផ្គង់ដែលមាននៅរតនាគារថ្នាក់កណ្ដាលដោយប្រើប្រាស់វិធីសាស្ត្រ System Check និង មិនមានអ្នកអនុម័តនោះទេ ។ ជាចុងក្រោយ រតនាគារថ្នាក់កណ្ដាលត្រូវជូនដំណឹងទៅអ្នកផ្គត់ផ្គង់ អំពីការបង្វែរការទូទាត់ចូលគណនីប្រាក់បញ្ញើអ្នកផ្គត់ផ្គង់ ។

២-បង្វែរទៅរតនាគាររាជធានី-ខេត្ត÷ ក្រោយពីទទួលបានការជូនដំណឹងអំពីការទូទាត់ចំណាយខាងលើ អ្នករៀបចំការទូទាត់ ត្រូវបង្កើតប្រតិបត្តិការទូទាត់សាច់ប្រាក់ក្នុងប្រព័ន្ធ FMIS ដោយប្រើប្រាស់វិធីសាស្ត្រ System Check និងជ្រើសរើស LIAS BANK រួចបញ្ជូនទៅកាន់អ្នកអនុម័តប្រតិបត្តិការទូទាត់ ដើម្បីពិនិត្យ និង អនុម័ត ។ ក្រោយប្រតិបត្តិការទូទាត់បានអនុម័តរួច អ្នកបង្កើតប្រតិបត្តិការត្រូវបោះពុម្ពប្រកាសឥណទាន ដើម្បីជូនដំណឹងទៅរតនាគាររាជធានី-ខេត្ត ។

ចំពោះដំណើការទូទាត់នៃកិច្ចប្រតិបត្តិការចំណាយខាងលើ ក្នុងករណីពិនិត្យឃើញថា ពុំទាន់មានលក្ខណៈត្រឹមត្រូវ និង មិនអនុលោមតាមបទប្បញ្ញត្តិផ្សេងៗនៃសេចក្ដីណែនាំនេះ មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអមក្រសួង-ស្ថាប័នទាំង ១៩ និង អគ្គនាយកដ្ឋានរតនាគារជាតិ មានសិទ្ធិស្នើសុំការបញ្ជាក់បំភ្លឺពីអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុនៃក្រសួង-ស្ថាប័នទាំង ១៩ ឬ អង្គភាពថវិកាជាអាណាប័កផ្ទេរសិទ្ធិពេញលេញនៅថ្នាក់កណ្ដាល ឬ ផ្ដល់ឯកសារបន្ថែម ឬ មិនធ្វើការទូទាត់ជូន ។ ក្នុងករណីបដិសេធការទូទាត់ ដោយសារពុំបានទទួលការបញ្ជាក់ ឬឯកសារបន្ថែមត្រឹមត្រូវ និង គ្រប់គ្រាន់ មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអមក្រសួង-ស្ថាប័នទាំង ១៩ ឬ អគ្គនាយកដ្ឋានរតនាគារជាតិ ត្រូវបញ្ជូនប្រតិបត្តិការចំណាយខាងលើត្រឡប់ទៅអាណាប័កវិញ ដោយមានការបញ្ជាក់អំពីចំណុចខ្វះខាត ។ ក្រោយពីការកែតម្រូវ ឬ ស្នេនបញ្ចូលបន្ថែមនូវលិខិតយុត្តិការចំណាយរួច អាណាប័កត្រូវបញ្ជូនប្រតិបត្តិការឡើងវិញក្នុងប្រព័ន្ធ FMIS ស្របតាមនីតិវិធី ។

ក្រសួង-ស្ថាប័នទាំង ១៩ ដូចមានបញ្ជាក់ក្នុងសេចក្ដីណែនាំនេះ និង គ្រប់អង្គភាពពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តតាមសេចក្ដីណែនាំនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃទី ១ ខែ តុលា ឆ្នាំ ២០២១ តទៅ ។

ថ្ងៃចន្ទ ៧ កើត ខែភទ្របទ ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០២១

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**ចម្លងជូន÷**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្ដម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី

  "ដើម្បីជូនជ្រាប"
- ក្រសួង-ស្ថាប័នទាំង១៩មានរៀបរាប់ខាងលើ
- អគ្គនាយកដ្ឋានថវិកា
- អគ្គនាយកដ្ឋានរតនាគារជាតិ

  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

*តារាងឧបសម្ព័ន្ធភ្ជាប់តាមសេចក្តីណែនាំលេខ......០១៣......ចុះថ្ងៃទី......១៣....តុលា....២០២១........*

*ស្តីពីការអនុវត្តនីតិវិធីថ្មីសម្រាប់ការចំណាយទូទាត់ត្រង់ដែលមានហានិភ័យទាបសម្រាប់ក្រសួង-ស្ថាប័នចំនួន ១៩*

*តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS)*

## តារាងសម្រង់លិខិតយុត្តិការចំណាយដែលត្រូវស្កេនបញ្ចូលក្នុងប្រព័ន្ធ FMIS តាមមុខសញ្ញាចំណាយទូទាត់ត្រង់ដែលមានហានិភ័យទាប

លិខិតយុត្តិការចំណាយសម្រាប់ការទូទាត់ត្រង់ ដូចមានរៀបរាប់នៅក្នុងសេចក្តីណែនាំនេះ ដែលនឹងត្រូវស្កេនបញ្ចូលក្នុងប្រព័ន្ធ FMIS ត្រូវបានកំណត់តាមប្រភេទមុខសញ្ញាចំណាយនីមួយៗ ដូចមានលម្អិតក្នុងតារាងខាងក្រោម ។ ប្រសិនបើការទូទាត់ជាបុរេប្រទាន ត្រូវស្កេនបញ្ចូលបន្ថែមក្នុងប្រព័ន្ធ FMIS នូវ**<u>លិខិតផ្តល់បុរេប្រទាន</u>** ដើម្បីងាយស្រួលដល់ការងារទូទាត់ជម្រះបញ្ជី ។ ដោយឡែក សម្រាប់អង្គភាពថវិកាជាអាណាប័កផ្ទេរសិទ្ធិដែលមិនទាន់ប្រើប្រាស់ប្រព័ន្ធ FMIS គឺត្រូវស្កេនបន្ថែមនូវឯកសារមួយចំនួនទៀតបញ្ចូលក្នុងប្រព័ន្ធ FMIS រួមមាន÷ (១)-អាណត្តិបើកប្រាក់ (២)-ដីកាអមលិខិតយុត្តិការ និង (៣)-លិខិតស្នើសុំទូទាត់ថវិកា ។

| ល.រ | មុខសញ្ញាចំណាយ | លិខិតយុត្តិការចំណាយ ដែលត្រូវស្កេនបញ្ចូលក្នុងប្រព័ន្ធ FMIS |
|---|---|---|
| ១ | ថ្លៃប្រើប្រាស់អគ្គិសនី (60061) | - វិក្កយបត្រអគ្គិសនី ពីអគ្គិសនីកម្ពុជា ឬ សាខាអគ្គិសនីកម្ពុជា<br>- តារាងសម្រង់លម្អិតវិក្កយបត្រ (ក្នុងករណីមានវិក្កយបត្រចាប់ពីចំនួន ២ ឡើងទៅ) ដោយមានបញ្ជាក់ពីប្រធានអង្គភាព |
| ២ | ថ្លៃប្រើប្រាស់ទឹកស្អាត (60062) | - វិក្កយបត្ររដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ឬ សាខារដ្ឋាករទឹកស្វយ័តខេត្ត<br>- តារាងសម្រង់លម្អិតវិក្កយបត្រ (ក្នុងករណីមានវិក្កយបត្រចាប់ពីចំនួន ២ ឡើងទៅ) ដោយមានបញ្ជាក់ពីប្រធានអង្គភាព |
| ៣ | ថ្លៃប្រមូលសំរាម និង កាកសំណល់ ដែលមានកិច្ចសន្យា ឬ កិច្ចព្រមព្រៀង (61011) | - វិក្កយបត្រប្រមូលសំរាម និង កាកសំណល់<br>- តារាងសម្រង់លម្អិតវិក្កយបត្រ (ក្នុងករណីមានវិក្កយបត្រចាប់ពីចំនួន ២ ឡើងទៅ) ដោយមានបញ្ជាក់ពីប្រធានអង្គភាព |
| ៤ | ប្រាក់កម្រៃភ្នាក់ងារបរទេសជាប់កិច្ចសន្យា ដែលមានគោលការណ៍ពីរាជរដ្ឋាភិបាល (61092) | - ប្រកាស ឬ សេចក្តីសម្រេច ទទួលស្គាល់ភ្នាក់ងារបរទេសជាប់កិច្ចសន្យា<br>- កិច្ចសន្យាការងារ<br>- បញ្ជីឈ្មោះភ្នាក់ងារបរទេសជាប់កិច្ចសន្យា |
| ៥ | ថ្លៃជាវសៀវភៅរាជកិច្ច ដែលផ្គត់ផ្គង់ដោយទីស្តីការគណៈរដ្ឋមន្ត្រី (61113) | - វិក្កយបត្រថ្លៃជាវសៀវភៅរាជកិច្ច<br>- តារាងសម្រង់លម្អិតវិក្កយបត្រ (ក្នុងករណីមានវិក្កយបត្រចាប់ពីចំនួន ២ ឡើងទៅ) ដោយមានបញ្ជាក់ពីប្រធានអង្គភាព |
| ៦ | សោហ៊ុយប្រៃសណីយ៍ (61141) | - វិក្កយបត្រសោហ៊ុយផ្ញើរសេវា, វិក្កយបត្រសេវាតេឡិច<br>- តារាងសម្រង់លម្អិតវិក្កយបត្រ (ក្នុងករណីមានវិក្កយបត្រចាប់ពីចំនួន ០២ ឡើងទៅ) ដោយមានបញ្ជាក់ពីប្រធានអង្គភាព |

៥

| | | |
|---|---|---|
| ៧ | សោហ៊ុយទូរគមនាគមន៍<br>(61142) | - វិក្កយបត្រទូរគមនាគមន៍កម្ពុជា ឬ សាខាខេត្ត (ករណីមានចំនួនតិចជាង ១០)<br>- តារាងសម្រង់លម្អិតវិក្កយបត្រ (ក្នុងករណីមានវិក្កយបត្រមានចំនួនចាប់ពី ១០ ឡើង) ដោយមានបញ្ជាក់ពីប្រធានអង្គភាព |
| ៨ | ប្រាក់អាហារូបករណ៍សម្រាប់ការសិក្សា និងស្រាវជ្រាវក្នុងប្រទេសដែលមានគោលរបបកំណត់<br>(62025) | - តារាងសម្រង់ឈ្មោះសិស្ស និស្សិតដែលទទួលប្រាក់អាហារូបករណ៍<br>- ប្រកាស ឬ សេចក្ដីសម្រេចផ្ដល់អាហារូបករណ៍ដល់ឈ្មោះសិស្ស និស្សិត |
| ៩ | ថ្លៃលតាប័ត្រសម្រាប់បង់ពន្ធយានយន្តប្រចាំឆ្នាំ (មធ្យោបាយដឹកជញ្ជូន)<br>(63011) | - តារាងលម្អិតសម្រង់យានយន្តរបស់រដ្ឋ ដែលត្រូវបង់ពន្ធ និងមានការបញ្ជាក់ទទួលស្គាល់ត្រឹមត្រូវពីពន្ធដារ |

២

*តារាងឧបសម្ព័ន្ធភ្ជាប់តាមសេចក្តីណែនាំលេខ......០១៣...... ចុះថ្ងៃទី.......១៣ កញ្ញា ២០២១......*
*ស្តីពីការអនុវត្តនីតិវិធីថ្មីសម្រាប់ការចំណាយទូទាត់ត្រង់ដែលមានហានិភ័យទាបសម្រាប់ក្រសួង-ស្ថាប័នចំនួន ១៩*
*តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS)*

# តារាងសម្រង់អ្នកផ្គត់ផ្គង់
# តាមមុខសញ្ញាចំណាយទូទាត់ត្រង់ដែលមានហានិភ័យទាប

បញ្ជីឈ្មោះ និង លេខកូដអ្នកផ្គត់ផ្គង់ក្នុងប្រព័ន្ធ FMIS ដែលមានរៀបរាប់នៅក្នុងសេចក្តីណែនាំនេះ ត្រូវបានកំណត់តាមប្រភេទមុខសញ្ញាចំណាយនីមួយៗ ដូចមានលម្អិតក្នុងតារាងខាងក្រោម និងត្រូវបានរាប់បញ្ចូលជាចំណាយទូទាត់ត្រង់ដែលមានហានិភ័យទាប ។ សម្រាប់អ្នកផ្គត់ផ្គង់ក្រៅពីតារាងខាងក្រោមមិនត្រូវបានរាប់បញ្ចូលជាអ្នកផ្គត់ផ្គង់ស្ថិតក្រោមចំណាយទូទាត់ត្រង់ដែលមានហានិភ័យទាបឡើយ ។

| ល.រ | មុខសញ្ញាចំណាយ | ឈ្មោះអ្នកផ្គត់ផ្គង់ (លេខកូដអ្នកផ្គត់ផ្គង់ក្នុងប្រព័ន្ធ FMIS) |
|---|---|---|
| ១ | ថ្លៃប្រើប្រាស់អគ្គិសនី<br>(60061) | - អគ្គិសនីកម្ពុជា (0000002623)<br>- អគ្គិសនីខេត្តបន្ទាយមានជ័យ (0000002856)<br>- អគ្គិសនីខេត្តកំពង់ចាម (0000002741)<br>- អគ្គិសនីខេត្តបាត់ដំបង (0000002777)<br>- អគ្គិសនីខេត្តរតនគីរី (0000002865)<br>- អគ្គិសនីខេត្តមណ្ឌលគីរី (0000002874)<br>- អគ្គិសនីខេត្តព្រះសីហនុ (0000002876)<br>- អគ្គិសនីខេត្តក្រចេះ (0000002877)<br>- អគ្គិសនីខេត្តតាកែវ (0000002909)<br>- អគ្គិសនីខេត្តស្វាយរៀង (0000002914)<br>- អគ្គិសនីខេត្តកំពង់ស្ពឺ (0000002956)<br>- អគ្គិសនីខេត្តព្រៃវែង (0000003000)<br>- អគ្គិសនីខេត្តសៀមរាប (0000003885)<br>- អគ្គិសនីខេត្តកំពត (0000004583)<br>- អគ្គិសនីខេត្តត្បូងឃ្មុំ (0000007875)<br>- អគ្គិសនីខេត្តកណ្តាល (0000008356)<br>- អគ្គិសនីខេត្តស្ទឹងត្រែង (0000008810) |

១

| | | |
|---|---|---|
| ២ | ថ្លៃប្រើប្រាស់ទឹកស្អាត<br>(60062) | - រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (0000002626)<br>- រដ្ឋាករទឹកស្វយ័តសៀមរាប (0000004274)<br>- រដ្ឋាករទឹកខេត្តបាត់ដំបង (0000002936)<br>- រដ្ឋាករទឹកខេត្តពោធិ៍សាត់ (0000002915)<br>- រដ្ឋាករទឹកខេត្តកំពត (0000002903)<br>- រដ្ឋាករទឹកខេត្តស្វាយរៀង (0000003822)<br>- រដ្ឋាករទឹកខេត្តមណ្ឌលគិរី (0000007927)<br>- រដ្ឋាករទឹកខេត្តស្ទឹងត្រែង (0000004853)<br>- រដ្ឋាករទឹកខេត្តកំពង់ចាម (0000002742)<br>- រដ្ឋាករទឹកខេត្តកំពង់ធំ (0000004905) |
| ៣ | ថ្លៃប្រមូលសំរាម និង កាកសំណល់រឹង រាវ ដែលមានកិច្ចសន្យា ឬ កិច្ចព្រមព្រៀង<br>(61011) | - ក្រុមហ៊ុន ស៊ីនទ្រី (ខេមបូឌា) ( 0000002504)<br>- រដ្ឋាករស្វយ័តគ្រប់គ្រងសំរាម និង សំណល់រឹង (0000008700) |
| ៤ | ប្រាក់កម្រៃភ្នាក់ងារបរទេសជាប់កិច្ចសន្យា ដែលមានគោលការណ៍ពីរាជរដ្ឋាភិបាល<br>(61092) | - មិនកំណត់ |
| ៥ | ថ្លៃជាវសៀវភៅរាជកិច្ច ដែលផ្គត់ផ្គង់ដោយទីស្តីការគណៈរដ្ឋមន្ត្រី<br>(61113) | - មិនកំណត់ |
| ៦ | សោហ៊ុយប្រៃសណីយ៍ ដែលផ្តល់សេវាដោយប្រៃសណីយ៍កម្ពុជា<br>(61141) | - ប្រៃសណីយ៍កម្ពុជា (0000002733) |
| ៧ | សោហ៊ុយទូរគមនាគមន៍ ដែលផ្គត់ផ្គង់ដោយក្រុមហ៊ុនទូរគមនាគមន៍កម្ពុជា<br>(61142) | - ទូរគមនាគមន៍កម្ពុជា (0000002628) |
| ៨ | ប្រាក់អាហារូបករណ៍សម្រាប់ការសិក្សា និង ស្រាវជ្រាវក្នុងប្រទេសដែលមានគោលរបបកំណត់<br>(62025) | - មិនកំណត់ |
| ៩ | ថ្លៃលតាប័ត្រសម្រាប់បង់ពន្ធយានយន្តប្រចាំឆ្នាំ (មធ្យោបាយដឹកជញ្ជូន)<br>(63011) | - មិនកំណត់ |